ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំង
អំពើជួញដូរមនុស្ស

លេខ៖ ✓...........................

# ញត្តិគាំទ្រ

## សារពិសេសរបស់ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន
## ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា អំពីក្របខណ្ឌកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍តំបន់ត្រីកោណ កម្ពុជា-ឡាវ-វៀតណាម(CLV-DTA)

យើងខ្ញុំទាំងអស់គ្នាជាថ្នាក់ដឹកនាំ និងមន្ត្រីនគរបាលជាតិ នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) សូមធ្វើការប្រកាសជាឱឡារិកគាំទ្រនូវសារសម្លេងពិសេសរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន ប្រធានគណបក្សប្រជាជនកម្ពុជា និងជាប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា** ដែលបានពន្យល់បន្ថែមយ៉ាងក្បោះក្បាយ អំពីកិច្ចសហប្រតិបត្តិការតំបន់ត្រីកោណអភិវឌ្ឍន៍កម្ពុជា-ឡាវ-វៀតណាម (CLV-DTA) ដល់ជនរួមជាតិទាំងអស់ នៅថ្ងៃទី១២ ខែសីហា ឆ្នាំ២០២៤ ។

យើងខ្ញុំទាំងអស់គ្នា សូមការពារដាច់ខាតរាជរដ្ឋាភិបាលស្របច្បាប់ ដែលកើតចេញពីការបោះឆ្នោតដោយប្រជាពលរដ្ឋ និងសូមថ្កោលទោសប្រឆាំងដាច់ខាត ចំពោះឧបាយកលទុច្ចរិតរបស់ពួកឧទ្ទាមខុសច្បាប់ ដែលបានញុះញង់ អុជអាល បំផ្លិចបំផ្លាញជាតិ បំផ្លាញសន្តិភាព ក្នុងគោលបំណងផ្តួលរំលំរាជរដ្ឋាភិបាលស្របច្បាប់ ដែលប្រសូតចេញពីការបោះឆ្នោត ដែលជាទង្វើបំពានច្បាប់ធ្ងន់ធ្ងរបំផុត ប្រឆាំងនឹងរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ជាពិសេសប្រឆាំងឆន្ទៈពលរដ្ឋ និងមានចេតនាបំផ្លិចបំផ្លាញសុខសន្តិភាព ដែលឥស្សរជនថ្នាក់ដឹកនាំកម្ពុជាមាន **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ជាស្ថាបនិកមគ្គុទេសក៍ឯក និងជាប្រតិបត្តិករនយោបាយ ឈ្នះ-ឈ្នះ បានយកសាច់ស្រស់ឈាមស្រស់ទៅប្តូរ ក្នុងការនាំមកនូវសុខសន្តិភាព និងការអភិវឌ្ឍន៍ ដែលកម្ពុជាទទួលបាននាពេលបច្ចុប្បន្ននេះ។

យើងខ្ញុំទាំងអស់គ្នា សូមប្តេជ្ញាគោរព និងការពាររដ្ឋធម្មនុញ្ញ ចូលរួមកសាងនីតិរដ្ឋ ការពារសុខសន្តិភាព ស្ថិរភាពសង្គម ជាពិសេសដំណើរការអភិវឌ្ឍន៍ប្រទេសជាតិប្រកបដោយចីរភាព មានសុខដុមរមនា នៅក្នុងសង្គម ស្របតាមកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាល នីតិកាលទី៧ នៃរដ្ឋសភា ដឹកនាំដោយ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** ដើម្បីដឹកនាំនាវាកម្ពុជា ឈានឆ្ពោះទៅការសម្រេចឱ្យបាននូវគោលដៅអភិវឌ្ឍន៍ ឆ្នាំ២០៣០ និងឆ្នាំ២០៥០ ។ ជាថ្មីម្តងទៀត ក្នុងនាមថ្នាក់ដឹកនាំ និងមន្ត្រីនគរបាលជាតិ នៃគណៈកម្មាធិការជាតិ (គ.ជ.ប.ជ) សូមធ្វើការប្តេជ្ញាការពារឱ្យខាងតែបាននូវសុខសន្តិភាព ស្ថិរភាពនយោបាយ និងសណ្តាប់ធ្នាប់សាធារណៈ ដើម្បីសេចក្តីសុខសាន្តរបស់ប្រជាជនកម្ពុជាគ្រប់រូបនៅទូទាំងប្រទេស ទោះស្ថិតក្នុងតម្លៃណាក៏ដោយ ។

ថ្ងៃពុធ ១០កើត ខែស្រាពណ៍ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨
រាជធានីភ្នំពេញ, ថ្ងៃទី ១៤ ខែសីហា ឆ្នាំ២០២៤
ជ.ប្រធានគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស
អនុប្រធានអចិន្ត្រៃយ៍

ជួ_ប៊ុនអេង